ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

តុលាការកំពូល
សភាព្រហ្មទណ្ឌ
សំណុំរឿងព្រហ្មទណ្ឌ
លេខ: ៧៨
ចុះថ្ងៃទី០៤ ខែធ្នូ ឆ្នាំ២០១៩
សាលដីកា
លេខ: ២១ "VIII"
ចុះថ្ងៃទី២៩ ខែមករា ឆ្នាំ២០២០

# សាលដីកា
## តាងនាមប្រជារាស្ត្រខ្មែរ
## តុលាការកំពូល

បានបើកសវនាការជាសាធារណៈ នៅថ្ងៃទី២២ ខែមករា ឆ្នាំ២០២០ ដោយមានសមាសភាពអង្គជំនុំជម្រះដូចខាងក្រោម ៖

១.លោក [redacted] ប្រធាន

២.លោក [redacted] ចៅក្រម

៣.លោក [redacted] ចៅក្រម

៤.លោក [redacted] ចៅក្រម

៥.លោកស្រី [redacted] ចៅក្រម

### ក្រឡាបញ្ជីសវនាការ

លោកស្រី [redacted]

### តំណាងមហាអយ្យការ

ឯកឧត្តម [redacted] អគ្គព្រះរាជអាជ្ញារង

### ដើម្បីជំនុំជម្រះ

លើបណ្តឹងសាទុក្ខលេខ ៣៨១ ចុះថ្ងៃទី០២ ខែធ្នូ ឆ្នាំ២០១៩ របស់លោក [redacted] សឹង្ហហេង មេធាវីការពារសិទ្ធិឱ្យជនត្រូវចោទឈ្មោះ [redacted] SHAO GUI និងឈ្មោះ [redacted] ZHEN JUN ចំពោះសាលដីកាព្រហ្មទណ្ឌលេខ ៩០ "ក្រ.III.ស.អ" ចុះថ្ងៃទី២០ ខែវិច្ឆិកា ឆ្នាំ២០១៩ របស់សភាស៊ើបសួរនៃសាលាឧទ្ធរណ៍ ដែលមាន៖

-ជនត្រូវចោទ៖



Scanned with CamScanner

១-ឈ្មោះ [redacted] SHAO GUI ភេទប្រុស អាយុ២៤ឆ្នាំ ជនជាតិចិន មុខរបរអ្នកចងការប្រាក់ ទីកន្លែងកំណើតនៅប្រទេសចិន ទីលំនៅមុនពេលឃាត់ខ្លួន [redacted] ខេត្តព្រះសីហនុ ឪពុកឈ្មោះ [redacted] "ស" ម្ដាយឈ្មោះ [redacted] "រ" នៅលីវ ជានីតិជន ទោសពីមុនគ្មាន (ក្នុងឃុំ) ។ (អ្នកប្ដឹងសាទុក្ខ)

-ឃុំខ្លួនតាមដីកាបង្គាប់ឲ្យឃុំខ្លួនបណ្ដោះអាសន្នលេខ ៣៥៧៤ ដ.ឃ.ខ/១៩ ចុះថ្ងៃទី២៣ ខែកក្កដា ឆ្នាំ២០១៩ នៅពន្ធនាគារ ឬមណ្ឌលឃុំខ្លួនខេត្តព្រះសីហនុ។

២-ឈ្មោះ [redacted] ZHEN JUN ភេទប្រុស អាយុ២១ឆ្នាំ ជនជាតិចិន មុខរបរអ្នកចងការប្រាក់ ទីកន្លែងកំណើតនៅប្រទេសចិន ទីលំនៅមុនពេលឃាត់ខ្លួន [redacted] ខេត្តព្រះសីហនុ ឪពុកឈ្មោះ [redacted] "រ" ម្ដាយឈ្មោះ [redacted] "រ" នៅលីវ ជានីតិជន ទោសពីមុនគ្មាន (ក្នុងឃុំ) ។ (អ្នកប្ដឹងសាទុក្ខ)

-ឃុំខ្លួនតាមដីកាបង្គាប់ឲ្យឃុំខ្លួនបណ្ដោះអាសន្នលេខ ៣៥៧៦ ដ.ឃ.ខ/១៩ ចុះថ្ងៃទី២៣ ខែកក្កដា ឆ្នាំ២០១៩ នៅពន្ធនាគារ ឬមណ្ឌលឃុំខ្លួនខេត្តព្រះសីហនុ។

លោក [redacted] **សឺន្ធហេង** ជាមេធាវីការពារសិទ្ធិឱ្យជនត្រូវចោទឈ្មោះ [redacted] SHAO GUI និង ឈ្មោះ [redacted] ZHEN JUN ។

មានលោក [redacted] **គឹមហុង** ជាមន្ត្រីពន្ធនាគារខេត្តព្រះសីហនុ អ្នកបកប្រែភាសា ។

<u>ត្រូវបានដាក់ឲ្យស្ថិតនៅក្រោមការពិនិត្យពីបទ:</u> **ចាប់ឃុំឃាំង និងបង្ខាំងដោយខុសច្បាប់** ប្រព្រឹត្តនៅផ្ទះសំណាក់រលកសមុទ្រខៀវ ស្ថិតនៅភូមិ៣ សង្កាត់លេខ៣ ក្រុងព្រះសីហនុ ខេត្តព្រះសីហនុ កាលពីថ្ងៃទី២១ ខែកក្កដា ឆ្នាំ២០១៩ វេលាម៉ោង ១៥ និង ៣០នាទី បទល្មើសព្រហ្មទណ្ឌដែលមានចែងឱ្យផ្ដន្ទាទោសតាមមាត្រា ២៥៣ ចំណុចទី ១ នៃក្រមព្រហ្មទណ្ឌ ។

-ដើមបណ្ដឹងរដ្ឋប្បវេណីឈ្មោះ [redacted] MEI YONG ភេទប្រុស អាយុ៤៨ឆ្នាំ ជនជាតិចិន មុខរបរកម្មករសំណង់ មានទីលំនៅបច្ចុប្បន្នស្នាក់នៅ [redacted] ខេត្តព្រះសីហនុ កម្រិតវប្បធម៌ មហាវិទ្យាល័យឆ្នាំទី៤ ។

### អំពីអង្គហេតុ:

កាលពីថ្ងៃទី២១ ខែកក្កដា ឆ្នាំ២០១៩ វេលាម៉ោង១៥ និង ៣០នាទី នៅចំណុចផ្ទះសំណាក់រលកសមុទ្រខៀវ ស្ថិតនៅភូមិ៣ សង្កាត់លេខ៣ ក្រុងព្រះសីហនុ ខេត្តព្រះសីហនុ មានករណីចាប់ឃុំឃាំង និងបង្ខាំងមនុស្សដោយខុសច្បាប់មួយបានកើតឡើង ប្រព្រឹត្តដោយជនសង្ស័យជាជនជាតិចិនពីរនាក់ មានឈ្មោះ [redacted] SHAO GUI ភេទប្រុស និងឈ្មោះ [redacted] ZHEN JUN ភេទប្រុស បានធ្វើសកម្មភាពចាប់ជនរងគ្រោះ [redacted] MEI YONG ភេទប្រុស អាយុ៤៨ឆ្នាំ ជនជាតិចិន ឡើងរ៉ឺម៉កកង់បី រួចយកទៅបង្ខាំងនៅផ្ទះសំណាក់រលកសមុទ្រខៀវ ជាន់ទី៤ បន្ទប់លេខ៤០៦ ។ បន្ទាប់មកជនរងគ្រោះបានលួចផ្ញើសារ



Scanned with CamScanner

(វីឆាត) ទៅប្រពន្ធរបស់ខ្លួនឱ្យជួយប្ដឹងសមត្ថកិច្ច ក្រោយមកកម្លាំងសមត្ថកិច្ចបានធ្វើការស្រាវជ្រាវកំណត់ទីតាំងដែលបង្ខាំងជនរងគ្រោះ និងធ្វើវដ្ដបាលឆែកឆេររំដោះជនរងគ្រោះ ហើយធ្វើការឃាត់ខ្លួនជនសង្ស័យពីរនាក់ខាងលើ ដោយដកហូតបានទូរស័ព្ទចំនួនពីរគ្រឿង (ម៉ាក VIVO ១ គ្រឿង និងម៉ាក SAMSUNG S8 ១ គ្រឿង) ។

-បានឃើញ ដីកាសម្រេចមិនអនុញ្ញាតឱ្យនៅក្រៅឃុំលេខ ១៣៤៦ តព/១៩ ចុះថ្ងៃទី១១ ខែកញ្ញា ឆ្នាំ២០១៩ របស់សាលាដំបូងខេត្តព្រះសីហនុ ដែលមានខ្លឹមសារនៃសេចក្ដីសម្រេចដូចតទៅ ៖

មិនអនុញ្ញាតឱ្យជនត្រូវចោទ៖

១.ឈ្មោះ [redacted] SHAO GUI ភេទប្រុស អាយុ២៣ឆ្នាំ ជនជាតិចិន ទីកន្លែងកំណើតនៅប្រទេសចិន ទីលំនៅបច្ចុប្បន្ន [redacted] ខេត្តព្រះសីហនុ មុខរបរអ្នកចងការប្រាក់នៅលើវ ឪពុកឈ្មោះ [redacted] "ស" ម្ដាយឈ្មោះ [redacted] "រ" ជានីតិជនទោសពីមុនគ្មាន ។

២.ឈ្មោះ [redacted] ZHEN JUN ភេទប្រុស អាយុ២០ឆ្នាំ ជនជាតិចិន ទីកន្លែងកំណើតនៅប្រទេសចិន ទីលំនៅមុនពេលឃាត់ខ្លួន [redacted] ខេត្តព្រះសីហនុ មុខរបរអ្នកចងការប្រាក់នៅលើវ ឪពុកឈ្មោះ [redacted] រ" ម្ដាយឈ្មោះ [redacted] "រ" ជានីតិជន ទោសពីមុនគ្មាន ។

ដែលត្រូវដាក់ឱ្យស្ថិតក្រោមការពិនិត្យពីបទ៖ ចាប់ឃុំឃាំង និងបង្ខាំងដោយខុសច្បាប់ ប្រព្រឹត្តនៅភូមិ៣ សង្កាត់លេខ៣ ក្រុងព្រះសីហនុ ខេត្តព្រះសីហនុ កាលពីថ្ងៃទី២១ ខែកក្កដា ឆ្នាំ២០១៩ បទល្មើសដែលមានចែងឱ្យផ្ដន្ទាទោសតាមបញ្ញត្តិមាត្រា ២៥៣ នៃក្រមព្រហ្មទណ្ឌ នៅក្រៅឃុំជាបណ្ដោះអាសន្ន ។

-បានឃើញសេចក្ដីចម្លងបណ្ដឹងឧទ្ធរណ៍លេខ ៧២ ចុះថ្ងៃទី១១ ខែតុលា ឆ្នាំ២០១៩ របស់លោក [redacted] សីង្ហហេង ជាមេធាវីការពារសិទ្ធិឱ្យជនត្រូវចោទឈ្មោះ [redacted] SHAO GUI និង [redacted] ZHEN JUN ដែលប្ដឹងមិនសុខចិត្តនឹងដីកាសម្រេចមិនអនុញ្ញាតឱ្យនៅក្រៅឃុំលេខ ១៣៤៦ តព/១៩ ចុះថ្ងៃទី១១ ខែកញ្ញា ឆ្នាំ២០១៩ របស់សាលាដំបូងខេត្តព្រះសីហនុ ត្រង់ចំណុចនៃសេចក្ដីសម្រេចទាំងមូល ។

-បានឃើញ សាលដីកាសភាស៊ើបសួរលេខ ៩០ ក្រIII "សអ" ចុះថ្ងៃទី២០ ខែវិច្ឆិកា ឆ្នាំ២០១៩ របស់សាលាឧទ្ធរណ៍ ដែលមានខ្លឹមសារនៃសេចក្ដីសម្រេចដូចតទៅ ៖

១-ទទួលសេចក្ដីចម្លងបណ្ដឹងឧទ្ធរណ៍លេខ ៧២ ចុះថ្ងៃទី១១ ខែតុលា ឆ្នាំ២០១៩ របស់ឈ្មោះ [redacted] សីង្ហហេង ជាមេធាវីការពារសិទ្ធិឱ្យជនត្រូវចោទ គឺត្រឹមត្រូវតាមទម្រង់ច្បាប់ តែបដិសេធចោលដោយខុសនឹងគតិច្បាប់ ។

២-តម្កល់ដីកាសម្រេចលេខ មិនអនុញ្ញាតឱ្យនៅក្រៅឃុំលេខ ១៣៤៦ តព/១៩ ចុះថ្ងៃទី១១ ខែកញ្ញា ឆ្នាំ២០១៩ របស់ចៅក្រមស៊ើបសួរនៃសាលាដំបូងខេត្តព្រះសីហនុ ទុកជាបានការដដែល ។



Scanned with CamScanner

៣-សាលដីកានេះបានប្រកាសជាអសាធារណៈនៅថ្ងៃទី២០ ខែវិច្ឆិកា ឆ្នាំ២០១៩ បើកសិទ្ធិប្តឹងសាទុក្ខក្នុងកំណត់ច្បាប់ ។

-បានឃើញបណ្តឹងសាទុក្ខលេខ ៣៨១ ចុះថ្ងៃទី០២ ខែធ្នូ ឆ្នាំ២០១៩ របស់មេធាវី [redacted] សឹង្ហហេង ដែលប្តឹងមិនសុខចិត្តនឹងសាលដីកាសភាស៊ើបសួរលេខ៩០ ក្រIII "សអ" ចុះថ្ងៃទី២០ ខែវិច្ឆិកា ឆ្នាំ២០១៩ របស់សាលាឧទ្ធរណ៍ ត្រង់ចំណុចនៃសេចក្តីសម្រេចទាំងមូល ។

## នាពេលសវនាការ

-ចៅក្រមបានអានរបាយការណ៍ ។

-តំណាងមហាអយ្យការអមតុលាការកំពូល ធ្វើសេចក្តីសន្និដ្ឋានសុំថា៖

-យល់ឃើញថា ការមិនអនុញ្ញាតឱ្យជនត្រូវចោទឈ្មោះ [redacted] SHAO GUI និងឈ្មោះ [redacted] ZHEN JUN នៅក្រៅឃុំនោះគឺជាការត្រឹមត្រូវស្របតាមមាត្រា ២០៥ នៃក្រមនីតិវិធីព្រហ្មទណ្ឌហើយ ។

ដូចនេះ សូមឱ្យក្រុមប្រឹក្សាជំនុំជម្រះពិនិត្យ និងសម្រេចតាមច្បាប់ ។

ហេតុដូច្នេះ តំណាងមហាអយ្យការប្តឹងសុំចំពោះតុលាការកំពូលឱ្យ៖

-ទទួលបណ្តឹងសាទុក្ខលេខ ៣៨១ ចុះថ្ងៃទី០២ ខែធ្នូ ឆ្នាំ២០១៩ របស់លោក [redacted] សឹង្ហហេង ជាមេធាវីការពារសិទ្ធិឱ្យជនត្រូវចោទឈ្មោះ [redacted] SHAO GUI និង [redacted] ZHEN JUN ទុកជាត្រឹមត្រូវតាមទម្រង់ច្បាប់ តែបដិសេធ ដោយខុសទៅនឹងគតិច្បាប់ ។

-តម្កល់សាលដីកាព្រហ្មទណ្ឌលេខ ៩០ ក្រIII "សអ" ចុះថ្ងៃទី២០ ខែវិច្ឆិកា ឆ្នាំ២០១៩ របស់សភាស៊ើបសួរសាលាឧទ្ធរណ៍ ទុកជាបានការដដែល ។

+លោក [redacted] សឹង្ហហេង ជាមេធាវីការពារសិទ្ធិឱ្យជនត្រូវចោទធ្វើសេចក្តីសន្និដ្ឋានថា៖ កូនក្តីខ្ញុំបាទបានជួបជាមួយនឹងជនរងគ្រោះនៅកាស៊ីណូមួយកន្លែង ហើយជនរងគ្រោះបាននាំកូនក្តីខ្ញុំទៅចាំ យកលុយនៅឯសណ្ឋាគារ ដោយប្រាប់ថាឱ្យគេយកលុយមកឱ្យ ស្រាប់តែជនរងគ្រោះទូរស័ព្ទទៅប្រាប់ប្រពន្ធថា កូនក្តីខ្ញុំចាប់បង្ខាំងរូបគាត់ ហើយពេលនោះក៏ត្រូវបានសមត្ថកិច្ចចុះមកឃាត់ខ្លួនកូនក្តីខ្ញុំបាទទាំងពីរតែម្តង ជនរងគ្រោះមិនមានរបួសស្នាមអ្វីទាំងអស់ កូនក្តីខ្លួនពុំមានចេតនាក្នុងការចាប់ ឬបង្ខាំងទុក ធ្វើទារុណកម្មលើជនរងគ្រោះនោះទេ ហើយមកដល់ពេលនេះគាត់បានចេញទៅប្រទេសចិនវិញបាត់ហើយ ចំពោះនីតិវិធីនៅសាលាដំបូងខេត្តព្រះសីហនុក៏ពុំទាន់បិទការស៊ើបសួរដែរ ហេតុដូច្នេះហើយទើបខ្ញុំបាទប្តឹងមកតុលាការកំពូល ។

<u>សំណូមពរ:</u> ស្នើសុំតុលាការអនុញ្ញាតឱ្យកូនក្តីខ្ញុំបាទនៅក្រៅឃុំជាបណ្តោះអាសន្ន ។

-ក្រោយពីបានស្តាប់របាយការណ៍របស់ចៅក្រមរបាយការណ៍

-ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋានរបស់តំណាងមហាអយ្យការ



Scanned with CamScanner

-ក្រោយពីបានស្តាប់ចម្លើយរបស់ជនត្រូវចោទ និងសេចក្តីសន្និដ្ឋានរបស់មេធាវីការពារសិទ្ធិឱ្យជនត្រូវចោទ

-ក្រោយពីបានពិភាក្សាត្រឹមត្រូវតាមច្បាប់ហើយ ។

## តុលាការកំពូល

១-យល់ឃើញថា បណ្តឹងសាទុក្ខលេខ ៣៨១ ចុះថ្ងៃទី០២ ខែធ្នូ ឆ្នាំ២០១៩ របស់លោក [redacted] សីន្ធុហេង មេធាវីការពារសិទ្ធិឱ្យជនត្រូវចោទឈ្មោះ [redacted] SHAO GUI និងឈ្មោះ [redacted] ZHEN JUN ធ្វើឡើងក្នុងកំណត់ច្បាប់ តុលាការកំពូលអាចលើករឿងនេះមកជំនុំជម្រះបានតាមមាត្រា៦៤ នៃច្បាប់ស្តីពីការរៀបចំអង្គការតុលាការ និងមាត្រា ៤២០ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ។

២-យល់ឃើញថា នាពេលសវនាការមេធាវីការពារសិទ្ធិឱ្យជនត្រូវចោទ បានសុំឱ្យតុលាការកំពូលសម្រេចឱ្យកូនក្តីខ្លួនបាននៅក្រៅឃុំជាបណ្តោះអាសន្ន ដោយសំអាងថា បទល្មើសដែលកូនក្តីខ្លួនបានប្រព្រឹត្តជាបទល្មើសមជ្ឈិម ហើយអំពើល្មើសដែលកូនក្តីខ្លួនបានប្រព្រឹត្តលើជនរងគ្រោះ ពុំមានចេតនាក្នុងការចាប់ ឬបង្ខាំងទុកធ្វើទារុណកម្មលើជនរងគ្រោះទេ នោះ តុលាការកំពូលពុំអាចពិចារណាបានទេ ពីព្រោះថា ថ្វីត្បិតបទចោទប្រកាន់លើជនត្រូវចោទជាបទមជ្ឈិមមែន ប៉ុន្តែ អំពើល្មើសរបស់ជនត្រូវចោទទាំងពីរនាក់ខាងលើនេះ ធ្វើឱ្យប៉ះពាល់ដល់សន្តិសុខ និងសណ្តាប់ធ្នាប់សង្គមយ៉ាងធ្ងន់ធ្ងរ ។ ដូច្នេះ ការដែលសភាស៊ើបសួរនៃសាលាឧទ្ធរណ៍ សម្រេចមិនឱ្យជនត្រូវចោទទាំងពីររូបខាងលើ បាននៅក្រៅឃុំបណ្តោះអាសន្ន នោះជាការសម្រេចសេចក្តីត្រឹមត្រូវស្របតាមស្មារតីមាត្រា ២០៥ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ។

៣-យល់ឃើញថា បណ្តឹងសាទុក្ខរបស់លោកមេធាវីការពារសិទ្ធិឱ្យជនត្រូវចោទ ពុំមានមូលហេតុសមស្របតាមមាត្រា ៤១៩ នៃក្រមនីតិវិធីព្រហ្មទណ្ឌទេ ។

៤-យល់ឃើញថា សាលដីកាព្រហ្មទណ្ឌលេខ ៩០ “ក្រ.III.ស.អ” ចុះថ្ងៃទី២០ ខែវិច្ឆិកា ឆ្នាំ២០១៩ របស់សភាស៊ើបសួរសាលាឧទ្ធរណ៍ ដែលបានសម្រេចមកនេះ ត្រឹមត្រូវតាមគតិច្បាប់ ។

## ហេតុដូច្នេះ
## សម្រេច

១-បដិសេធបណ្តឹងសាទុក្ខលេខ ៣៨១ ចុះថ្ងៃទី០២ ខែធ្នូ ឆ្នាំ២០១៩ របស់លោក [redacted] សីខហេង្ឋ មេធាវីការពារសិទ្ធិឱ្យជនត្រូវចោទឈ្មោះ [redacted] SHAO GUI និងឈ្មោះ [redacted] ZHEN JUN ។

២-តម្កល់សាលដីកាព្រហ្មទណ្ឌលេខ ៩០ “ក្រ.III.ស.អ” ចុះថ្ងៃទី២០ ខែវិច្ឆិកា ឆ្នាំ២០១៩ របស់សភាស៊ើបសួរសាលាឧទ្ធរណ៍ ទុកជាបានការពេញទាំងមូល ។



Scanned with CamScanner

៣-សាលដីកានេះ ជំនុំជម្រះជាសាធារណៈនៅថ្ងៃទី២២ ខែមករា ឆ្នាំ២០២០ និងប្រកាសជាសាធារណៈនៅថ្ងៃទី២៩ ខែមករា ឆ្នាំ២០២០ ។

Scanned with CamScanner